ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# លិខិតជូនពរ

**សូមគោរពជូន**

**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**
**ក្នុងឱកាសនៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២២**

***សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់***

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១១១ នៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២២ នេះ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមអបអរសាទរដោយសេចក្តីសោមនស្សរីករាយក្រៃលែង និងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ជូន **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា សូម **សម្ដេច** ទទួលបាននូវសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ ជ័យជម្នះគ្រប់ប្រការ និងវៀរចាកផុតពីរោគាព្យាធិគ្រប់ពេលវេលា ដើម្បីបន្តដឹកនាំស្ថាប័នកាកបាទក្រហមកម្ពុជាឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។

ក្នុងឱកាសនៃទិវានារីអន្តរជាតិដ៏ថ្លៃថ្លានិងមានអត្ថន័យនេះ យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ដោយស្មោះអស់ពីដួងចិត្ត ដែលជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូប ចំពោះស្នាដៃប៉ិនប្រសប់និង ធំធេងក្នុងកិច្ចការបម្រើជាតិ និងប្រជាជនខ្មែរ ដោយបានយកអស់នូវកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី និងពលិកម្មគ្រប់បែបយ៉ាងក្នុងការដឹកនាំស្ថាប័នកាកបាទក្រហមកម្ពុជា ដើម្បីការងារមនុស្សធម៌ដ៏ថ្លៃថ្លា ប្រកបដោយគុណធម៌និងសប្បុរសធម៌ ជួយដោះស្រាយទុក្ខលំបាករបស់ប្រជាជន គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង។ ជាពិសេស **សម្ដេច** បានខិតខំលើកកម្ពស់តម្លៃសីលធម៌សង្គមខ្មែរ តម្លៃនិងសិទ្ធិស្ត្រី និងគ្រួសារខ្មែរបានខ្ពង់ខ្ពស់ និងរុងរឿង។ ទាំងនេះបង្ហាញឱ្យឃើញយ៉ាងប្រត្យក្សថា **សម្ដេច** គឺជាស្ត្រីខ្មែរដ៏ឆ្នើមមួយរូបដែលជា ភរិយានិងជាមាតាដ៏ប្រសើរឧត្តម និងជាគំរូដល់ស្ត្រីនិងគ្រួសារខ្មែរទូទៅ។

យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូម **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** និង **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងសមប្រកបនូវព្រះពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ សុក្រ ២ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រំ.សុខា